# ហេតុអ្វីមនុស្សជាតិជាសង្គមវង្វេង

រាងកាយលោកធាតុដែលធំមហិមា, បណ្ដាអាទិទេព, ស្ដេច, ម្ចាស់សុទ្ធតែមិនដឹងបានខាងក្រៅ, ចំនួនជីវិតច្រើនសុទ្ធតែលេខរាប់មិនអស់។ ទោះបីជាជីវិតទាំងអស់ក្នុងរាងកាយលោកធាតុ, នៅក្នុងជាន់ថ្នាក់ឋិតនៅនៃសមាសភាពសារធាតុខ្លួនឯងសុទ្ធតែជាមើលឃើញគ្រប់ទិសទីតាំងនៃពិភពដែលខ្លួនឯងបានរស់រាន, ដូចបែបវិធីជាមួយអាទិទេពមើលពិភព, គ្រាន់តែជាគ្មានបញ្ញានិងសមត្ថភាពរបស់អាទិទេព។ ដូច្នោះក៏មានន័យថាជីវិតដែលក្នុងចក្រវាលរាងកាយលោកធាតុសុទ្ធតែនឹងមិនដូចជាស្ថានភាពរបស់មនុស្សជាតិ, មើលមិនឃើញសេចក្ដីពិតនៃពិភពដែលខ្លួនឯងរស់រាន, មើលមិនឃើញអត្ថិភាពរបស់ទម្រង់ជីវិតផ្សេងក្នុងបរិយាកាសដែលខ្លួនឯងរស់រាន, មើលមិនឃើញការបង្ហាញមែនទែននៃសារធាតុក្នុងបរិយាកាសដែលខ្លួនឯងបានរស់រាន។ ហេតុនេះបែបវិធីផ្ទត់គំនិត, បែបវិធីយល់ដឹងពិភពលោករបស់មនុស្សគឺជាពិសេសមានតែមួយហើយគ្មានសមត្ថភាព។ នេះជាក់ស្ដែងគឺសង្គមនៃ 「វង្វេង」 (លើកលែងតែមានតែអាទិទេពដើមមាននៃខាងក្នុងត្រៃភពនិងបាតុភូតដោយឡែកនៃពិភពបួសហាត់)។

ហេតុអ្វីបានជាបែបនេះ? គឺដោយសាររាងកាយលោកធាតុនិងខ្សែប្រព័ន្ធចក្រវាលជាច្រើនខាងក្នុងរាងកាយលោកធាតុ, សុទ្ធតែនៅក្នុងបទច្បាប់របស់កកើត, នឹងថេរ, អន្តរាយ, វិនាសដើរដល់ជំហានរបស់វិនាសចុងក្រោយរួចហើយ។ នៅក្នុងបែកបាក់នៃពេលវិនាសចុងក្រោយដែលគួរឲ្យខ្លាច, គ្រប់យ៉ាងនឹងវិនាសរលីងនិងគ្មាននៅ, ហេតុនេះម្ចាស់បង្កើតលោកសម្រេចចិត្តសង្គ្រោះប្រោសសត្វលោក។

រាងកាយលោកធាតុចក្រវាលនឹងដើរដល់ជំហានរបស់វិនាស, គឺជា

រាងកាយលោកធាតុជាមួយនឹងចក្រវាលជាច្រើនខាងក្នុងរាងកាយលោកធាតុនិងអនេកសត្វលោកក្នុងនោះ, រួមបញ្ចូលទាំងម្ចាស់ជាច្រើន, ស្តេចជាច្រើន, អាទិទេពជាច្រើនខាងក្នុងបណ្តាចក្រវាល, នៅក្នុងដំណើរការយូរអង្វែងរបស់កកើត, នឹងថេរ, អន្តរាយ, វិនាស, សុទ្ធតែប្រែជាមិនល្អដូចពេលកកើតដំបូង, ក៏មានន័យថាក្នុងឆ្នាំខែយូរអង្វែងសុទ្ធតែមិនសមស្របនឹងបរមាណើយនៃជាន់ថ្នាក់ដែលខ្លួនឯងឋិតនៅ។ នេះជាបទច្បាប់ចៀសមិនរួចក្នុងដំណើរការជីវិត។

ម្ចាស់បង្កើតលោកដើម្បីរំដោះសង្គ្រោះសត្វលោក, ហេតុនេះបានបើកបង្កើតពិភពមួយដែលនៅខាងក្រៅរបស់រាងកាយលោកធាតុ, ប្រើវាសង្គ្រោះប្រោសអនេកសត្វលោកខាងក្នុងរាងកាយលោកធាតុ, ហៅថា 「ត្រៃភព」។ នៅក្នុងត្រៃភពមាន៣ជាន់ថ្នាក់ដែលជីវិតស្ថិតនៅ, ជីវិតនៃជាន់ទាបបំផុតទាំងស្រុងគឺរស់រាននៅក្នុងបរិយាកាសដែលគ្មានសមត្ថភាព, វង្វេងបំផុតដែលគ្មានបញ្ញា, បរិយាកាសដែលទុក្ខបំផុត, នេះជាក់ស្តែងគឺជាសង្គមមនុស្សជាតិ។ ទោះបីជាមនុស្សនឹងសត្វលោករបស់ជាន់ទី២, បញ្ញានោះគ្រាន់តែខ្ពស់ជាងមនុស្សជាតិមួយជាន់ថ្នាក់នេះ, ដូច្នេះគ្រាន់តែអាចមើលឃើញមនុស្សជាតិនិងកាលៈទេសៈរបស់កម្រិតភពឋិតនៅរបស់ពួកគាត់ខ្លួនឯង, មនុស្សជាតិហៅនោះថាមនុស្សលើមេឃ។ ហើយមួយជាន់ខ្ពស់ជាងទៀតអាចមើលឃើញកាលៈទេសៈដែលជីវិតនៃ២ពិភពខាងក្រោមរស់រាននិងកាលៈទេសៈរបស់កម្រិតភពខ្លួនឯង, បញ្ញាក៏ជាខ្ពស់បំផុតខាងក្នុងត្រៃភព, មនុស្សជាតិហៅនោះជាទូទៅថាមនុស្សមេឃ។ ប៉ុន្តែសត្វលោកខាងក្នុងត្រៃភពសុទ្ធតែគ្មានសមត្ថភាពមើលឃើញចក្រវាលពិតប្រាកដនឹងពិភពឋានសួគ៌ដែលអាទិទេពឋិតនៅ។

ដូច្នេះមនុស្សជាតិរស់រាននៅ 「ក្នុងវង្វេង」 ដែលបញ្ញាតូចបំផុតនិង

មើលមិនឃើញធាតុពិតរបស់រឿងការណ៍។ នេះគឺនៅមុនពេលនៃវិនាសរលើងចុងបញ្ចប់, ម្ចាស់បង្កើតលោកដើម្បីការត្រួសត្រាយរបស់សត្វលោកអាចបានសង្គ្រោះ។ ក៏ជាទុកឲ្យសត្វលោកនៅក្នុងពិភពទុក្ខដែលមិនភ្លឺ, ពឹងផ្អែកករុណារបស់ចរិតមនុស្សដើរចេញមក។ ពិបាកគឺដ៏ពិបាក, នៅចុងបញ្ចប់របស់កកើត, នឹងថេរ, អន្តរាយ, វិនាស, ជីវិតដែលគួរត្រូវបានកម្ទេចចោលមានតែនៅក្នុងរងទុក្ខរំលាយកម្មដើម្បីដើរចេញមក, ក្នុងពេលដំណាលគ្នាម្តងទៀតអាចរក្សាជាប់ចរិតដើមល្អករុណាទើបអាចត្រូវបានទទួលស្គាល់ដោយ「អនាគត」។ចុងបញ្ចប់ដល់កាលណា, ម្ចាស់បង្កើតលោកយល់ព្រមឲ្យអាទិទេព, ស្តេច, ម្ចាស់ជាច្រើនជាមួយនឹងបណ្តាមហាអាទិទេព, មហាត្រាស់ដឹងធំមហិមាជាងទៀតដែលទទួលបន្ទុកនៃទិសមួយនៃរាងកាយលោកធាតុចុះលោកីយ៍ចាប់ជាតិជាមនុស្ស, បិទបាំងជាប់បញ្ញានិងសមត្ថភាពទាំងអស់របស់ពួកគាត់, នៅខាងក្នុងកាយមនុស្សដែលទុក្ខបំផុតគ្មានសមត្ថភាពបំផុត, គ្មានបញ្ញា, បិទបាំងជិតទាំងស្រុងរងទុក្ខរំលាយកម្ម, នៅក្នុងទុក្ខពឹងផ្អែកគំនិតសុចរិតរក្សាជាប់នូវចរិតដើមល្អករុណា, នោះទើបអាចត្រូវបានអាទិទេពជាច្រើនជាមួយម្ចាស់បង្កើតលោកយកចិត្តទុកដាក់, ទើបនឹងត្រូវបានអនាគតទទួលស្គាល់។ មនុស្សទាំងនោះដែលចាប់ជាតិច្រំដែលនៅក្នុងសង្គមមនុស្សជាតិបន្តិចម្តងៗរំលាយទៅទោសកម្មនិងករុណាគុណធម៌មួយថ្ងៃកាន់តែច្រើនក្នុងសង្គ្រោះប្រោសពោលគឺត្រូវបានជ្រើសរើសចំ, ចុងនៃចុងបញ្ចប់ពេលចាប់ផ្តើមសង្គ្រោះប្រោស, ជាក់លាក់នឹងត្រូវបានម្ចាស់បង្កើតលោកសង្គ្រោះប្រោសដល់ចក្រវាលថ្មី។ ដូច្នោះក៏មានន័យថា, បែបវិធីអត្ថិភាព「វង្វេង」របស់សង្គមមនុស្សជាតិ, គឺម្ចាស់បង្កើតលោកដើម្បីរំដោះសង្គ្រោះសត្វលោកហើយបើកបង្កើតសង្គមពិសេសជាក់លាក់នឹងបែបវិធី

ជីវិតរស់បាន។ ដូច្នេះមនុស្សនៅក្នុងវង្វេង, មិនថាចង់សុំនរណាបំបែកវង្វេងសុទ្ធតែគ្មានប្រយោជន៍។ ពីមេឃដល់ដីគ្មានជីវិតណាមួយហ៊ានបំផ្លាញបរិយាកាសសង្គ្រោះប្រោសសត្វលោកនេះ។

ក្នុងមនុស្សលោករមែងមានមនុស្សនិយាយជឿអាទិទេពគឺជាអបិយជំនឿ។ ដូច្នេះមានមនុស្សនិយាយមើលឃើញខ្ញុំនឹងជឿ, មើលមិនឃើញគឺមិនជឿ។ ហេតុនេះមានមនុស្សហ៊ានធ្វើរឿងអាក្រក់ហើយមិនគិតផលវិបាក។ មិនថាអាទិទេពខ្ពស់ដល់ណាចាប់ជាតិធ្វើជាមនុស្ស, មានកាយមនុស្សរួចហើយជាក់ស្តែងគឺជាមនុស្ស, ឈានចូលក្នុងកាយមនុស្សជាក់ស្តែងគឺឈានចូលក្នុងវង្វេងរួចហើយ, ហេតុនេះមានមនុស្សនឹងសាងកម្មនៅក្នុងវង្វេង។ ម្ចាស់បង្កើតលោកបង្កត្រៃភពគឺដើម្បីទុកឲ្យសត្វលោកក្នុងទុក្ខរំលាយទោសកម្ម, លើកកម្ពស់សីលធម៌របស់ខ្លួនឯងទើបជាគោលបំណងមូលដ្ឋាន, គ្មានទោសកម្មទើបអាចបានសង្គ្រោះត្រឡប់ទៅឋានសួគ៌។ សាងកម្មរួចហើយគឺត្រូវតែសងកម្ម, នេះគឺបានសម្រេចចិត្តដោយទ្រឹស្តីធម៌របស់រាងកាយលោកធាតុចក្រវាល។ ប៉ុន្តែមនុស្សនៅក្នុងវង្វេង, ទំនងណាស់ម្តងទៀតបានសាងទោសកម្មទីមនុស្សលោក, នោះប្រាកដណាស់ត្រូវការសង។ ជាតិនេះមិនសង, ជាតិក្រោយសង។ ភាពពិតមានមនុស្សដ៏ច្រើនទោសកម្មធំធ្ងន់ធ្ងរ, ដើម្បីមនុស្សអាចបានសង្គ្រោះ, ម្ចាស់បង្កើតលោកក៏នឹងជំនួសឲ្យមនុស្សរងទុក្ខឈឺចាប់មួយផ្នែក, នេះគឺជាមេត្តាធំបំផុតក្តីស្រឡាញ់ដែលធំបំផុតពោះសត្វលោក។ កម្មធំដល់កម្រិតជាក់លាក់, ជីវិតគឺនឹងពិតជាត្រូវបានបំផ្លាញចោល។ រំលាយទៅទោសកម្មត្រឡប់ទៅមេឃទើបជាគោលបំណងពិតប្រាកដលោកអ្នកមកលោកីយ៍។ នរណាៗពេលមកលោកីយ៍ចាប់ជាតិសុទ្ធតែធ្លាប់ស្បថសច្ចាចំពោះម្ចាស់បង្កើតលោក។ សងទោសកម្មប្រាកដណាស់នឹងពិបាកទ្រាំ

ណាស់, អំណាចកម្មនឹងធ្វើឲ្យមនុស្សប្រជែងប្រយុទ្ធ, នឹងមានសង្គ្រាម, នឹងមានជំងឺ, នឹងលំបាកនឿយហត់, នឹងមានអត់ឃ្លាន, នឹងមានក្រីក្រ, ហេតុនេះហើយទុក្ខឈឺចាប់។ ទោសកម្មប្រាកដណាស់ក៏មានធំមានតូច, ក៏ត្រង់ដោយសារមានកម្មធំកម្មតូច, ជីវិតមនុស្សទើបមានខុសគ្នារវាងក្រ និងមាន។ មនុស្សនៅក្នុងវង្វេងរក្សាជាប់ល្អករុណាគឺនឹងសាងកម្មតិច! រង ទុក្ខតិច!

ក៏មានន័យថា「វង្វេង」របស់មនុស្សត្រូវបានបង្កគឺជាដើម្បីសង្គ្រោះសត្វលោក, រំដោះសង្គ្រោះរាងកាយលោកធាតុជាមួយបណ្ដាចក្រវាល។「វង្វេង」នេះមានមូលហេតុដែលសំខាន់ធំយ៉ាងនេះ, ហេតុនេះក៏ដាច់ខាតនឹងមិនបណ្ដោយតាមចិត្តមនុស្សហើយបំបែកវង្វេង។ អាទិទេពលើលោកីយ៍ច្រើនណាស់, ហេតុអ្វីមិនបំពេញតណ្ហារបស់មនុស្សបំបែកវង្វេង? ពួកគាត់មិនហ៊ានទេ! នោះគឺម្ចាស់បង្កើតលោកបើកបង្កើតដើម្បីសង្គ្រោះរាងកាយលោកធាតុនិងសត្វលោក, នេះជាក្ដីសង្ឃឹមបានសង្គ្រោះរបស់សត្វលោក។

*លោកគ្រូ៖ លីហុងជឺ*
*ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៤*

បកប្រែពីភាសាដើមចិន៖

https://www.minghui.org/mh/articles/2024/9/30/483472.html

មានពិគ្រោះការបកប្រែជាភាសាអង់គ្លេស៖

https://en.minghui.org/html/articles/2024/10/1/221091.html

*បកប្រែថ្ងៃទី០២ ខែតុលា ឆ្នាំ២០២៤---កែសម្រួលថ្ងៃទី៣០ ខែសីហា ឆ្នាំ២០២៦។*